**ធម្មទេសនារបស់លោកអភិបាលអូលីវីយេ**
**អភិបូជាបុណ្យព្រះយេស៊ូប្រសូតជាមួយបុគ្គលិកការិយាល័យនៅភ្នំពេញថ្មី**
**ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៨**
*យើងស្តាប់ និងអនុវត្តព្រះបន្ទូលក្នុងការងារប្រចាំថ្ងៃ*

អត្ថបទទី១៖ អស ៤៨,១៧-១៩
ដំណឹងល្អ៖ មថ ១១,១៦-១៩

បងប្អូនជាទីស្រឡាញ់!

ព្រះយេស៊ូកំពុងឆ្ងល់ ដោយសារប្រជាជនដែលស្តាប់ព្រះអង្គចេះតែរិះគន់ នៅពេលគេឃើញលោកយ៉ូហានបាទីស្ត ដែលតមអាហារ អត់ហូបសុរា គេថាមនុស្សនេះបីដូចមនុស្សប្លែក វង្វេង ឆ្កួត។ ពេលគេឃើញព្រះយេស៊ូ ចូលរួមជប់លៀងជាមួយគេ ញ៉ាំអាហារជាមួយ និងពិសាសុរា គេថាមើលចុះអ្នកនោះគិតតែស៊ីផឹក ហើយសេពគប់ជាមួយអ្នកទារពន្ធ។ យើងគិតម៉េច? ពេលតមគេរិះគន់ ពេលញ៉ាំគេរិះគន់ គេអត់ដែលសប្បាយចិត្តទេ។ ប៉ុន្តែព្រះយេស៊ូរំឭកដល់យើងនៅថ្ងៃនេះថា "**ព្រះប្រាជ្ញាញាណរបស់ព្រះជាម្ចាស់ ពិតជាល្អត្រឹមត្រូវមែន ដោយយើងបានឃើញកិច្ចការដែលព្រះអង្គធ្វើ**"។ ខ្ញុំគិតថា សម្រាប់យើងជាការិយាល័យ ជាពេលវេលាមួយដើម្បីអង្គុយពិចារណាដែរ អំពីអ្វីដែលយើងបានធ្វើក្នុងភូមិភាគភ្នំពេញពេញមួយឆ្នាំ។

នៅថ្ងៃនេះ នៅពេលយើងវាយតម្លៃ ជាឱកាសមួយដើម្បីយើងគិតនៅក្នុងឆ្នាំ២០១៨ **តើយើងបានធ្វើអ្វីខ្លះ ដែលត្រូវនឹងព្រះហឫទ័យព្រះជាម្ចាស់? តើយើងបានធ្វើអ្វីខ្លះ ដើម្បីណែនាំឲ្យមនុស្សលោកសប្បាយឬមិនសប្បាយ?** ឲ្យយើងធ្វើប្រយ័ត្ន ដោយសារទស្សនៈរបស់ព្រះយេស៊ូ ព្រះបន្ទូលរបស់ព្រះយេស៊ូច្រើនលើកច្រើនសារ ផ្ទុយនឹងធម្មជាតិរបស់មនុស្សលោក។ ព្រះយេស៊ូនៅក្នុងជីវិតរបស់ព្រះអង្គ បានណែនាំឲ្យប្រជាជនអន់ចិត្ត ជាពិសេសគណៈផារីស៊ី ធម្មាចារ្យ ពួកធម្មវិន័យ ដោយសារព្រះអង្គណែនាំឲ្យគេគិតពិចារណាអំពីជីវិត និងស្នាដៃរបស់គេ និងអ្វីៗទាំងអស់ដែលគេខិតខំប្រព្រឹត្តតាមពន្លឺនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ដូច្នេះ សម្រាប់ការងាររបស់យើង ជីវិតរបស់យើង យើងមិនអាចដឹកនាំដោយទស្សនៈរបស់យើងផ្ទាល់ ប៉ុន្តែដឹកនាំដោយនឹកឃើញអំពីព្រះប្រាជ្ញាញាណរបស់ព្រះជាម្ចាស់ ដោយនឹកឃើញព្រះបន្ទូលរបស់ព្រះជាម្ចាស់បំភ្លឺយើងយ៉ាងដូចម្តេច។

នៅក្នុងអត្ថបទទី១ គឺ "**យើងនេះហើយ ជាព្រះជាម្ចាស់ ជាព្រះរបស់អ្នក យើងប្រៀនប្រដៅអ្នកអំពីអ្វីៗដែលមានប្រយោជន៍ដល់អ្នក យើងណែនាំឲ្យអ្នកដើរនៅក្នុងមាគ៌ាដែលអ្នកកំពុងតែដើរ។ ប្រសិនបើអ្នកយកចិត្តទុកដាក់ធ្វើតាមសេចក្ដីដែលយើងបង្គាប់ នោះសេចក្ដីសុខសាន្តមុខជាហូរមកលើអ្នកដូចទឹកទន្លេ**"។ ព្រះជាម្ចាស់ ព្រះអង្គសន្យា បង្រៀន បំភ្លឺ ហើយព្រះអង្គមានទស្សនៈសម្រាប់យើងម្នាក់ៗ។ ប្រសិនបើយើងធ្វើតាម យើងពោរពេញដោយសេចក្ដីសុខសាន្តនិងសេចក្ដីសុចរិត។ ថ្ងៃនេះ ឲ្យយើងស្ដាប់បង្គាប់ព្រះជាម្ចាស់ ស្ដាប់ធម្មវិន័យរបស់ព្រះយេស៊ូ។ យើងដឹងហើយធម្មវិន័យរបស់ព្រះយេស៊ូគឺ «**ស្រឡាញ់គ្នាទៅវិញទៅមកដូចខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ**»។ ប្រសិនបើយើងស្ដាប់បង្គាប់ហ្នឹង ពីមួយអាទិត្យទៅមួយអាទិត្យ យើងស្ដាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ហើយគិត **តើព្រះបន្ទូលនេះបំភ្លឺជីវិតការងារប្រចាំថ្ងៃរបស់ខ្ញុំផ្ទាល់ដូចម្ដេច?** ណែនាំឲ្យយើងអាចពោរពេញដោយសេចក្ដីសង្ឃឹម និងជាពិសេសពោរពេញដោយសេចក្ដីសុខសាន្ត។

យើងអធិដ្ឋានម្ដងទៀត ឲ្យយើងយកចិត្តទុកដាក់ស្ដាប់បង្គាប់ព្រះយេស៊ូ បានយកចិត្តទុកដាក់ធ្វើតាមតួនាទីរបស់ខ្លួន បានយកចិត្តទុកដាក់រស់នៅតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់ យើងពោរពេញដោយសេចក្ដីសុចរិតនិងសេចក្ដីសុខសាន្ត។ ចាប់ពីថ្ងៃនេះតទៅ យើងយកចិត្តទុកដាក់ថែមទៀត ដើម្បីរស់នៅជាមួយសេចក្ដីសុខ និងសេចក្ដីសុចរិតរបស់ព្រះជាម្ចាស់ និងយកចិត្តទុកដាក់ស្ដាប់ព្រះបន្ទូលនិងអនុវត្តតាម។ អាម៉ែន៕